**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**<u>ព័ត៌មានពិស្តារនៃការដាក់ឯកសារ</u>**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | 00២/១៩-0៩-២00៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | **អង់គ្លេស** |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 20-Jun-2012, 14:47
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ អៀង សារី ស្នើសុំឲ្យមានការប្រជុំរៀបចំសវនាការមួយ ដើម្បីពិភាក្សាពីលទ្ធភាពនៃការអនុវត្ត ការចូលបើកមើលឯកសារនៅក្នុង S-Drive ពីចម្ងាយ**

---

| <u>អ្នកដាក់ឯកសារ:</u> | <u>អ្នកទទួលឯកសារ:</u> | <u>ចម្លងជូន:</u> |
|---|---|---|
| សហព្រះរាជអាជ្ញា: | អង្គជំនុំជម្រះសាលាដំបូង: | ជនជាប់ចោទ: |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | នួន ជា |
| | ចៅក្រម យ៉ា សុខន | អៀង សារី |
| | ចៅក្រមJean-Marc LAVERGNE | ខៀវ សំផន |
| | ចៅក្រម យូ ឧត្តរា | |
| | | មេធាវីការពារក្ដីជនជាប់ចោទ: |
| | សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី: | លោក សុន អរុណ |
| | ពេជ អង្គ | លោក Michiel PESTMAN |
| | | លោក Victor Koppe |
| | | លោក អាង ឧត្តម |

Elisabeth SIMONNEAU FORT

លោក Michael G.KARNAVAS
លោក គង់ សំអុន
លោក Arthur VERCKEN
Anta GUISSE
លោក Jacques VERGÈS

## ចម្លើយតប

១. នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១២ មេធាវីការពារក្តីរបស់ អៀង សារី ("មេធាវីការពារក្តី") មេធាវីការពារក្តីបានដាក់សំណើរបស់ខ្លួន ស្នើសុំឲ្យមានការប្រជុំរៀបចំសវនាការតាមទម្រង់ការមួយ ដើម្បីពិភាក្សាអំពីលទ្ធភាពនៃការអនុវត្តការចូលបើកមើលឯកសារនៅក្នុង S-Drive ពីចម្ងាយ ("សំណើ")។ មេធាវីការពារក្តីស្នើសុំថា តាមវិធាន៧៩.៧ នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះសាលាដំបូងបានកំណត់កាលវិភាគមួយដើម្បីធ្វើការប្រជុំរៀបចំសវនាការតាមទម្រង់ការមួយ ក្នុងគោលបំណងដើម្បីពិគ្រោះយោបល់ពីលទ្ធភាពក្នុងការអនុវត្តការចូលបើកមើលឯកសារនៅក្នុង S-Drive ពីចម្ងាយ។

សហព្រះរាជអាជ្ញាគាំទ្រចំពោះសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីដែលថា លទ្ធភាពចូលពិនិត្យមើលឯកសារក្នុង S-Drive ពីចម្ងាយនឹងបានជាជំនួយដ៏ធំធេងដល់ការងាររបស់គ្រប់ភាគីទាំងអស់ ទាំងការបង្កើនប្រសិទ្ធិភាពឲ្យបានជាអតិបរមា និងទាំងការធានាចំពោះសុវត្ថិភាពនៃសំណុំឯកសារដែលមានលក្ខណៈរសើបនៃសំណុំរឿងផងដែរ។ ដូចមេធាវីការពារក្តីបានកត់សំគាល់ដែរ សហព្រះរាជអាជ្ញាធ្លាប់បានចូលរួមជាមួយភាគីដទៃទៀតកាលពីលើកមុនៗ ក្នុងការស្នើសុំឲ្យការិយាល័យរដ្ឋបាលជាអ្នកសម្របសម្រួលចំពោះលទ្ធភាពនេះ។ ជាការបន្ថែម ការបិទការិយាល័យ អ.វ.ត.ក នៅកណ្តាលក្រុង ពេលនេះកាន់តែធ្វើឲ្យតម្រូវការក្នុងការចូលពិនិត្យមើលឯកសារក្នុង S-Drive ពីចម្ងាយកាន់តែមានសារសំខាន់ថែមទៀតដល់ការងាររបស់ភាគីទាំងអស់។ ការធ្វើដំណើរយ៉ាងច្រើន និងកង្វះលទ្ធភាពទទួលបានបរិក្ខាផ្សេងៗដើម្បីបង្កលក្ខណៈងាយស្រួលសំរាប់ធ្វើការងារក្រៅម៉ោង ធ្វើឲ្យមានការលំបាកយ៉ាងខ្លាំងដល់បុគ្គលិកមកធ្វើការនៅតុលាការនៅចុងសប្តាហ៍ និងនៅពេលល្ងាច។ ការណ៍នេះ ចោទជាបញ្ហាជាពិសេសនៅក្នុងរយៈពេលនៃសវនាការជំនុំជម្រះ នៅពេលដែលក្រុមបុគ្គលិកត្រូវចូលរួមក្នុងសាលសវនាការពេញម៉ោង ហើយត្រូវបន្តត្រៀមរៀបចំដើម្បីសួរដេញដោលនៅពេលខ្លួននៅក្រៅម៉ោងសវនាការ ដែលរួមទាំងនៅចុងសប្តាហ៍ផង។

២. សហព្រះរាជអាជ្ញា សូមជួយលើកឡើងម្តងទៀតចំពោះសំណើមេធាវីការពារក្តីដែលសុំឲ្យមានការអនុវត្តនូវការបើកឲ្យចូលមើលឯកសារនៅក្នុងS-Drive ពីចម្ងាយបាន និងសូមគាំទ្រទាំងស្រុងចំពោះសំណើរបស់មេធាវីការពារក្តីដែលសុំឲ្យមានការប្រជុំសវនាការផ្លូវការមួយដើម្បីដោះស្រាយលើបញ្ហាមួយចំនួនក្នុងរឿងនេះ។

## ឧបាស្រ័យដែលបានស្នើសុំ

៣. តាមស្មារតីនៃអ្វីៗដែលមានពីមុនមក សហព្រះរាជអាជ្ញា ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង មេត្តា៖

កំណត់កាលបរិច្ឆេទនៃការប្រជុំសវនាការផ្លូវការមួយ ដើម្បីដោះស្រាយអំពីបញ្ហានេះឲ្យបានយ៉ាងឆាប់បំផុតតាមដែលអាចអនុវត្តបាន៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |